**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**

លេខ ៤៦៥ ទសដណ.ទសក

ថ្ងៃ ច័ន្ទ ១១កើត ខែ កត្តិក ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែ វិច្ឆិកា ឆ្នាំ២០២១

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអនុញ្ញាតឱ្យទេសចរអន្តរជាតិ និងអ្នកដំណើរដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ពេញលេញ ចូលក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនតម្រូវឱ្យធ្វើចត្តាឡីស័ក

យោងសេចក្តីជូនដំណឹងលេខ៤៩៩ សខល. ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ក្រសួងសុខាភិបាល និងគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ ក្រសួងទេសចរណ៍មានកិត្តិយស និងសេចក្តីរីករាយ សូមជម្រាបជូនដំណឹងដល់ប្រតិបត្តិករទេសចរណ៍ ទេសចរអន្តរជាតិ និងអ្នកដំណើរទាំងអស់ មេត្តាជ្រាបថា **ចាប់ពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១** នេះតទៅ រាជរដ្ឋាភិបាលកម្ពុជាអនុញ្ញាតឱ្យទេសចរអន្តរជាតិ និងអ្នកដំណើរពីក្រៅប្រទេសចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា **ដោយមិនតម្រូវឱ្យធ្វើចត្តាឡីស័កឡើយ** ដោយត្រូវអនុវត្តតាមការណែនាំ ដូចខាងក្រោម៖

១. **ទេសចរអន្តរជាតិ និងអ្នកដំណើរ** ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ដូសមូលដ្ឋានពេញលេញ ហើយចូលមកកម្ពុជាតាមផ្លូវអាកាស,ផ្លូវគោក និងផ្លូវទឹកត្រូវភ្ជាប់មកជាមួយនូវបណ្ណឬវិញ្ញាបនបត្រចាក់**វ៉ាក់សាំងកូវីដ-១៩** ដែលបញ្ជាក់ពីការចាក់វ៉ាក់សាំងកូវីដ-១៩ដូសមូលដ្ឋានពេញលេញ និងវិញ្ញាបនបត្របញ្ជាក់ថាគ្មានកូវីដ-១៩ (ដោយម៉ាស៊ីន PCR) ដែលមានសុពលភាពរយៈពេល**៧២ម៉ោង** និងទទួលស្គាល់ដោយអាជ្ញាធរសុខាភិបាលនៃប្រទេសសាម៉ី។ **ពេលមកដល់កម្ពុជា**, ទេសចរតម្រូវឱ្យធ្វើតេស្តរហ័សកូវីដ១៩ (COVID-19 Rapid Test) អនុវត្តដោយមន្ត្រីសុខាភិបាលនៅតាមច្រកទ្វារចេញ-ចូលកម្ពុជា ហើយត្រូវរង់ចាំលទ្ធផលតេស្តរហ័សរយៈពេលពី**១៥ ទៅ ២០**នាទីសិន។ បន្ទាប់ពីតេស្តរហ័សបង្ហាញលទ្ធផលអវិជ្ជមាន ទេសចរអាចធ្វើដំណើរបានដោយសេរីនៅទូទាំងកម្ពុជា **ដោយមិនកម្រិតតំបន់ ឬខេត្ត ក្រុងនោះទេ និងមិនតម្រូវឱ្យធ្វើចត្តាឡីស័កឡើយ**។

២. **ទេសចរអន្តរជាតិ និងអ្នកដំណើរ** ដែលមិនបានចាក់វ៉ាក់សាំងកូវីដ-១៩ ហើយធ្វើដំណើរចូលមកកម្ពុជា **តម្រូវឱ្យយកសំណាកដើម្បីធ្វើតេស្តដោយម៉ាស៊ីនPCR** នៅតាមច្រកទ្វារចេញ-ចូលកម្ពុជា និងត្រូវធ្វើចត្តាឡីស័កពេញលេញរយៈពេល១៤ថ្ងៃ ស្របទៅតាមនីតិវិធីជាធរមាន។

៣. **ទេសចរអន្តរជាតិនិងអ្នកដំណើរ** ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋានពេញលេញ ហើយកំពុងធ្វើចត្តាឡីស័កនៅតាមមណ្ឌលចត្តាឡីស័ក, សណ្ឋាគារ និងគេហដ្ឋាននៅទូទាំងប្រទេស និងដែលមិនមានវិជ្ជមានកូវីដ-១៩ ត្រូវបានអនុញ្ញាតឱ្យចេញពីការធ្វើចត្តាឡីស័ក ចាប់ពីថ្ងៃទី**១៥ ខែវិច្ឆិកា ឆ្នាំ២០២១** នេះតទៅ។

ក្រសួងទេសចរណ៍មានកិត្តិយសសូមជម្រាបជូនថា កម្ពុជាបានចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋបានរហូតដល់ជិត៨៨%នៃចំនួនប្រជាជនសរុប**១៦លាន**នាក់រួចហើយ បច្ចុប្បន្ន កំពុងផ្តល់ជូននូវវ៉ាក់សាំងដូសជំរុញថែមទៀត និងបន្តយុទ្ធនាការចាក់វ៉ាក់សាំងដល់កុមារអាយុ០៥ឆ្នាំផងដែរ។

អគារលេខ៣A ផ្លូវលេខ១១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧៤ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

ភាពជោគជ័យនៃយុទ្ធនាការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋនៅទូទាំងប្រទេស បានបង្កើតនូវភាពស៊ាំក្នុងសហគមន៍យ៉ាងរឹងមាំ ដែលអនុញ្ញាតឱ្យកម្ពុជាអាចបើកស្តារសេដ្ឋកិច្ច-សង្គមពេញលេញឡើងវិញ ក្នុងនោះរួមមានវិស័យទេសចរណ៍ផងដែរ។

បច្ចុប្បន្ន **ទេសចរផ្ទៃក្នុង** បាននិងកំពុងធ្វើចលនាយ៉ាងទូលំទូលាយនៅទូទាំងប្រទេសប្រកបដោយសុវត្ថិភាព និងភាពសប្បាយរីករាយ។

**កម្ពុជា ព្រះរាជាណាចក្រអច្ឆរិយៈ** សូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះ**ភ្ញៀវទេសចរអន្តរជាតិ និងអ្នកដំណើរ** ដែលបានចាក់វ៉ាក់សាំងកូវីដ-១៩ដូសមូលដ្ឋានពេញលេញ ចូលមកទស្សនាព្រះរាជាណាចក្រកម្ពុជាតាមគ្រប់ច្រកទ្វារអន្តរជាតិផ្លូវអាកាស ផ្លូវគោកនិងផ្លូវទឹក និងគ្រប់គោលដៅទេសចរណ៍ទាំងអស់។ៗ

**រដ្ឋមន្ត្រី**

**ថោង ខុន**